អាជ្ញាធរអគ្គិសនីកម្ពុជា

ELECTRICITY AUTHORITY OF CAMBODIA

ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

ELECTRICITY LAW OF THE KINGDOM OF CAMBODIA

# សេចក្តីសម្រេចកែសម្រួលលើកទី៦
# លើឯកសារអាជ្ញាប័ណ្ណ លេខ ០៨៥ ឯអ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៣
# សម្រាប់សហគ្រាស អេឡិកត្រិស៊ីធី ត្បូងឃ្មុំ ធ្វើសេវាកម្មអគ្គិសនី នៅតំបន់ស្រុកត្បូងឃ្មុំ និងនៅតំបន់ស្រុកអូររាំងឪ ខេត្តកំពង់ចាម
# សម្រាប់ការបង្កើនអាណត្តិ និងប្តូរប្រភេទអាជ្ញាប័ណ្ណ

# DECISION ON THE SIXTH REVISION
## OF THE LICENSE DOCUMENT No. 085 LD DATED DECEMBER 29, 2003 OF ELECTRICITY TBONG KHMUM ENTERPRISE FOR PROVIDING ELECTRIC POWER SERVICES AT TBONG KHMUM DISTRICT AND OREANG OV DISTRICT, KAMPONG CHAM PROVINCE

# FOR INCREASING TERM OF LICENSE AND CHANGING LICENSE TYPE

ថ្ងៃទី ខែ ឆ្នាំ២០១០

, 2010

# ផ្នែកទី១
# សេចក្តីសម្រេចផ្តល់សិទ្ធិឱ្យធ្វើសេវាកម្ម

# PART 1
# DECISION TO GRANT THE RIGHT TO PROVIDE THE ELECTRIC POWER SERVICE

ព្រះរាជាណាចក្រកម្ពុជា

KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ

NATION RELIGION KING

អាជ្ញាធរអគ្គិសនីកម្ពុជា

ELECTRICITY AUTHORITY OF CAMBODIA

លេខ : -១០ អអក

# សេចក្តីសម្រេចកែសម្រួលលើកទី៦ លើឯកសារអាជ្ញាប័ណ្ណ លេខ ០៨៥ ឯអ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៣ សម្រាប់សហគ្រាស អេឡិកទ្រីស៊ីធី ត្បូងឃ្មុំ

# DECISION ON THE SIXTH REVISION OF THE LICENSE DOCUMENT No. 085 LD DATED DECEMBER 29, 2003 OF ELECTRICITY TBONG KHMUM ENTERPRISE

## អាជ្ញាធរអគ្គិសនីកម្ពុជា

## ELECTRICITY AUTHORITY OF CAMBODIA

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស.រកម.០២០១.០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

-In exercise of the powers conferred by Article 7 and 35 of the Electricity Law promulgated by the Royal Decree No. NS/RKM/0201/03 dated 02 February 2001.

-យោងឯកសារអាជ្ញាប័ណ្ណរួមលេខ ០៨៥ ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញឱ្យសហគ្រាស អេឡិកទ្រីស៊ីធី ត្បូងឃ្មុំ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៣

-Refer to the Consolidated License No. 085 LD issued by Electricity Authority of Cambodia on December 29, 2003.

-យោងលិខិតស្នើសុំកែសម្រួលអាជ្ញាប័ណ្ណរបស់សហគ្រាស អេឡិកទ្រីស៊ីធី ត្បូងឃ្មុំ លេខ ០០១/១០ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ ២០១០

- In accordance with the requested letter for license revision from Tboung Khmum Enterprise No 001/10 dated January 04, 2010.

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី ខែ ឆ្នាំ២០១០ ដល់ថ្ងៃទី ខែ ឆ្នាំ២០១០

-In accordance with the consultation with concerned parties and public, made from ...., 2010 to ....., 2010.

-យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១០

- In accordance with the decision of Electricity Authority of Cambodia's Session No..., dated ......., 2010.

## **សម្រេច**

## DECIDES

**ប្រការ១**

កែសម្រួលឯកសារអាជ្ញាប័ណ្ណរួមលេខ ០៨៥ ឯអ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៣ ដែលបានផ្តល់ជូនសហគ្រាស **អេឡិកទ្រីស៊ីធី ត្បូងឃ្មុំ** (បន្ទាប់ពីនេះហៅថា "**អ្នកកាន់អាជ្ញាប័ណ្ណ**) សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅតំបន់ស្រុកត្បូងឃ្មុំ និងតំបន់ស្រុកអូររាំងឪ ខេត្តកំពង់ចាម សម្រាប់ផ្តល់សិទ្ធិឱ្យអ្នកកាន់អាជ្ញាប័ណ្ណដូចខាងក្រោម ៖

ក) ដោយសារអ្នកកាន់អាជ្ញាប័ណ្ណបានសាងសង់ខ្សែបណ្តាញថ្មី និងបានកែលំអខ្សែបណ្តាញដែលមានស្រាប់ ស្របតាមស្តង់ដាបច្ចេកទេសអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចបង្កើនអាណត្តិអាជ្ញាប័ណ្ណពី ១០(ដប់)ឆ្នាំ ទៅ ១៥(ដប់ប្រាំ)ឆ្នាំ។ អាណត្តិថ្មីរបស់អាជ្ញាប័ណ្ណនេះ មានរយៈពេល១៥(ដប់ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខាតទៅ និងអាចស្នើសុំបន្តទៀត ឬស្នើសុំកែសម្រួលលើកលែងតែត្រូវដកហូតដោយអនុលោមតាមល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ។

ខ) ប្តូរប្រភេទអាជ្ញាប័ណ្ណពីអាជ្ញាប័ណ្ណរួម ដែលរួមមានអាជ្ញាប័ណ្ណផលិត និងអាជ្ញាប័ណ្ណចែកចាយ មកជាអាជ្ញាប័ណ្ណរួម ដែលរួមមានអាជ្ញាប័ណ្ណចែកចាយសម្រាប់ធ្វើសេវាកម្មចែកចាយលើតំបន់ចែកចាយដែលមានស្រាប់ និងអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស។ ការបន្ថែមអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសនេះ សម្រាប់ផ្តល់សិទ្ធិឱ្យអ្នកកាន់អាជ្ញាប័ណ្ណដូចខាងក្រោម ៖

- គ្រប់គ្រង និងដំណើរការខ្សែបណ្តាញមេ ២២ គីឡូវ៉ុល នៅតាមបណ្តោយផ្លូវជាតិលេខ៧ ចាប់ពីតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជាខេត្តកំពង់ចាម រហូតដល់តំបន់ចែកចាយរបស់សហគ្រាស អេឡិកទ្រីស៊ីធី សួង និងតាមបណ្តោយផ្លូវជាតិលេខ១១ ចាប់ពីផ្សារថ្នល់ទទឹង រហូតដល់តំបន់ចែកចាយរបស់លោក ឃុន សុផល និងខ្សែបណ្តាញបំបែកចេញពីខ្សែបណ្តាញមេ ។
- លក់ដុំឱ្យអ្នកកាន់អាជ្ញាប័ណ្ណ និងអាចលក់ដុំឱ្យអតិថិជន MV ដទៃទៀត ដែលនៅក្បែរគន្លងនៃខ្សែបណ្តាញ 22kV ក្នុងចម្ងាយអនុញ្ញាតដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល លេខ៧៨៤ ឧរថ.អថ.ប្រក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦ ដែលមានបំណងទិញដុំពីប្រព័ន្ធរបស់ក្រុមហ៊ុន ឱ្យតែការលក់នីមួយៗនេះ គោរពតាមគោលការណ៍ និងបានទទួលការអនុញ្ញាតដោយឡែកមួយៗ ពីអាជ្ញាធរអគ្គិសនីកម្ពុជា។

**Article 1**

To revise the consolidated license document No. 085 LD dated December 29, 2003 issued to Tbong Khmum Enterprise (herein after referred to as **"Licensee"**) in order to supply the electric power services at Tbong Khmum District and Oreang Ov District, Kampong Cham Province by giving right to licensee to:

As the licensee has installed new networks and improved existing facilities by replacing new facilities in accordance with Electric Power Technical Standards of the Kingdom of Cambodia, EAC decides to increase the term of license from 10(ten) years to 15(fifteen) years. The new term of license shall come into force from the date of signing and may be renewed for further periods unless revoked earlier in accordance with the conditions of license.

a) Changing the type of license from Consolidated License consisting of Production License and Distribution License to Consolidated License consisting of Distribution License for providing electric power service at existing distribution area and Special Purpose Transmission License for granting right to the licensee as follows:

-Own and operate 22 kV main lines along the National Road No. 7 from the distribution area of Electricité du Cambodge (EDC) in Kampong Cham Province to the distribution area of Electricity Suong Enterprise and along the National Road No. 11 from Phsar Thnal Toteng to the distribution area of Mr. Khun Sophal and the brand lines.

-To sale electricity to licensees (having authorized distribution area) and be able to sell electric power energy to MV consumers, along the route of 22kV lines within the length authorized by Prakas of Ministry of Industry, Mines and Energy No. 784 dated July 21, 2006, who wish to purchase electricity in bulk from the lines of the Company and each purchasing shall comply with the principal and get approval for each purchasing from EAC.

**ប្រការ២**

ប្រការ១(ក) ក្នុងផ្នែកទី១ និងឧបសម្ព័ន្ធទី២ នៃឯកសារអាជ្ញាប័ណ្ណលេខ ០៨៥ ឯអ ត្រូវបានលុបចេញពីឯកសារអាជ្ញាប័ណ្ណលេខ ០៨៥ ឯអ ។

**Article 2**

Article 1 (a) of Part I and Schedule 2 of the license documents No. 085 LD is deleted.

| | |
|---|---|
| **ប្រការ៣**<br>ខ្លឹមសារផ្នែកទី២ នៃឯកសារអាជ្ញាប័ណ្ណលេខ ០៨៥ ឯអ ត្រូវជំនួសដោយខ្លឹមសារផ្នែកទី២ កែសម្រួលថ្មីដូចមានភ្ជាប់មកជាមួយ ។ | **Article 3**<br>Part II of the license document No. 085 LD is replaced by the new revised Part II attached herewith. |
| **ប្រការ៤**<br>ខ្លឹមសារដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ ០៨៥ ឯអ ត្រូវស្ថិតនៅជាធរមានដដែល ។ | **Article 4**<br>The other contents of the license document No. 085 LD shall remain in force. |
| **ប្រការ៥**<br>សេចក្តីសម្រេចនេះ និងឯកសារផ្នែកទី២ កែសម្រួលថ្មី ត្រូវចាត់ទុកជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ០៨៥ ឯអ ។ | **Article 5**<br>This decision and new revised part II shall be considered as a part of the license documents No. 085 LD. |
| **ប្រការ៦**<br>សេចក្តីសម្រេចនេះ ត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ | **Article6**<br>The decision shall come into force from the date of signing. |
| **ប្រការ៧**<br>អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្តីសម្រេចនេះទៅតម្កល់ទុកបន្ថែមនៅតាមទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ០៨៥ ឯអ បានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណលេខ ០៨៥ ឯអ ដែលតម្កល់មានការកែសម្រួលជាថ្មីស្របតាមសេចក្តីសម្រេចនេះ ។ | **Article 7**<br>The licensee shall send this decision to deposit additionally at the places, where the license document No. 085 LD has been deposited in order that the deposited license document No. 085 LD is in conformity with this decision. |

ភ្នំពេញ, ថ្ងៃទី.... ខែ..... ឆ្នាំ២០១០

Phnom Penh, .................., 2010

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

CHAIRMAN OF EAC

# ផ្នែកទី២

# លក្ខខណ្ឌរបស់អាជ្ញាប័ណ្ណ

# PART II

# CONDITIONS OF LICENSE

# តារាងមាតិកា

## TABLE OF CONTENTS


| | |
|---|---|
| **១ និយមន័យរបស់ពាក្យប្រើក្នុងអាជ្ញាប័ណ្ណ** | **1 Definitions of Terms used in the License** |
| **២ កាតព្វកិច្ចទូទៅរបស់អ្នកកាន់អាជ្ញាប័ណ្ណ** | **2 General Obligation of Licensee** |
| ល័ក្ខខ័ណ្ឌទី១ : កាតព្វកិច្ចគោរពច្បាប់ អនុក្រឹត្យ បទបញ្ជានិងកិច្ចព្រមព្រៀងបញ្ជូន | Condition 1: Obligation on compliance with the Laws, Sub-Decrees, Orders and Wheeling Agreement |
| ល័ក្ខខ័ណ្ឌទី២ : កាតព្វកិច្ចគោរពតាមស្តង់ដាបច្ចេកទេស សុវត្ថិភាព និងបរិស្ថាន | Condition 2: Obligation on compliance with technical standard, Safety and Environment |
| ល័ក្ខខ័ណ្ឌទី៣ : ល័ក្ខខ័ណ្ឌចំពោះការធ្វើអាជីវកម្ម | Condition 3: Conditions on the Business |
| ល័ក្ខខ័ណ្ឌទី៤ : កាតព្វកិច្ចធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សកម្មភាពសេវាកម្មរបស់ខ្លួន តាមការកំណត់របស់អាជ្ញាធរអគ្គិសនីកម្ពុជា | Condition4: Obligation on Financial statement and reports on electric power service required by EAC |
| ល័ក្ខខ័ណ្ឌទី៥ : កាតព្វកិច្ចបង់កម្រៃអាជ្ញាប័ណ្ណ | Condition5: Obligation on payment of license fee |
| ល័ក្ខខ័ណ្ឌទី៦ : សុខុមាលភាព និងសុវត្ថិភាពនៃនិយោជិត | Condition 6: Health and Safety of Employees |
| ល័ក្ខខ័ណ្ឌទី៧ : ការទំនាក់ទំនង | Condition 7: Communication |
| ល័ក្ខខ័ណ្ឌទី៨ : ល័ក្ខខ័ណ្ឌលក់មធ្យោបាយចែកចាយ និងមធ្យោបាយបញ្ជូនរងអគ្គិសនីក្នុងករណីមានការតម្រូវពីអាជ្ញាធរអគ្គិសនីកម្ពុជា | Condition 8: Sale Condition of distribution and sub-transmission facilities in the case it is the required from EAC |
| **៣_ល័ក្ខខ័ណ្ឌសេវាកម្មសម្រាប់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស** | **3- Service Conditions for Special Purpose Transmission License** |
| ល័ក្ខខ័ណ្ឌទី៩ : ល័ក្ខខ័ណ្ឌចំពោះមធ្យោបាយបញ្ជូនអគ្គិសនី/មធ្យោបាយបញ្ជូនរងអគ្គិសនី | Condition 9: Condition on Transmission/ Sub-Transmission Facilities |
| ល័ក្ខខ័ណ្ឌទី១០ :ល័ក្ខខ័ណ្ឌដំណើរការមធ្យោបាយបញ្ជូនអគ្គិសនី/មធ្យោបាយបញ្ជូនរងអគ្គិសនី | Condition 10: Condition on Operation of Sub-Transmission Facilities |
| ល័ក្ខខ័ណ្ឌទី១១ :ល័ក្ខខ័ណ្ឌចំពោះការបើកចំហសិទ្ធិប្រើប្រាស់ និងសិទ្ធិភ្ជាប់ជាមួយមធ្យោបាយបញ្ជូនអគ្គិសនី/មធ្យោបាយបញ្ជូនរងអគ្គិសនីដោយមិនរើសអើង | Condition 11: Condition on providing Non-discriminatory Open Access and connection to Sub-Transmission Facilities |
| ល័ក្ខខ័ណ្ឌទី១២ :ល័ក្ខខ័ណ្ឌគោរពតាមកូដប្រព័ន្ធបញ្ជូន កូដប្រព័ន្ធចែកចាយ និងស្តង់ដាដំណើរការ | Condition 12: Conditions on compliance with Grid Code, Distribution Codes and Operating Standard |
| ល័ក្ខខ័ណ្ឌទី១៣ :ល័ក្ខខ័ណ្ឌចំពោះថ្លៃលក់អគ្គិសនីសម្រាប់សេវាកម្មបញ្ជូន និងសេវាកម្មលក់ដុំ | Condition 13: Condition on Tariff for transmission/wheeling service and Bulk Sale |
| ល័ក្ខខ័ណ្ឌទី១៤ :ការដោះស្រាយវិវាទពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងបញ្ជូន ឬកិច្ចព្រមព្រៀងផ្គត់ផ្គង់អគ្គិសនី | Condition 14: Settlement of Disputes relating to Transmission / Wheeling or Supply Agreement |
| **៤_ ល័ក្ខខ័ណ្ឌសេវាកម្មសម្រាប់អាជ្ញាប័ណ្ណចែកចាយ** | **4- Service Conditions for Distribution License** |
| ល័ក្ខខ័ណ្ឌទី១៥ : ល័ក្ខខ័ណ្ឌចំពោះតំបន់ធ្វើសេវាកម្ម | Condition 15: Condition on electric power service area |
| ល័ក្ខខ័ណ្ឌទី១៦ : ល័ក្ខខ័ណ្ឌចំពោះមធ្យោបាយធ្វើសេវាកម្ម | Condition 16: Conditions on electric power service utilities |
| ល័ក្ខខ័ណ្ឌទី១៧ : ល័ក្ខខ័ណ្ឌចំពោះកិច្ចដំណើរការប្រព័ន្ធចែកចាយ | Condition17: Conditions on distribution system operation |
| ល័ក្ខខ័ណ្ឌទី១៨ : ល័ក្ខខ័ណ្ឌចំពោះការផ្គត់ផ្គង់អគ្គិសនីឱ្យអតិថិជន | Condition 18: Condition on electric power supply to customer |
| **ឧបសម្ព័ន្ធទី១** : ពត៌មាននៃប្រព័ន្ធបញ្ជូនរងអគ្គិសនីដែលអនុញ្ញាត | |

| | |
|---|---|
| **ឧបសម្ព័ន្ធទី២ :** តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី<br>**ឧបសម្ព័ន្ធទី៣ :** ល័ក្ខខ័ណ្ឌសម្រាប់ធ្វើការដកហូតអាជ្ញាប័ណ្ណ<br>**ឧបសម្ព័ន្ធទី៤ :** ម្ចាស់កម្មសិទ្ធិនៃអ្នកកាន់អាជ្ញាប័ណ្ណ | **SCHEDULE 1:** Details of Authorized Sub-transmission System<br>**SCHEDULE 2:** Authorized Distributing Area<br>**SCHEDULE 3:** Term of License Revocation<br>**SCHEDULE 4:** Ownership of Licensee |

# លក្ខខណ្ឌនៃអាជ្ញាប័ណ្ណ

# CONDITIONS OF LICENSE

| | |
|---|---|
| **១-និយមន័យរបស់ពាក្យប្រើក្នុងអាជ្ញាប័ណ្ណ** | **1-DEFINITIONS OF TERMS USED IN THE LICENSE** |
| ពាក្យពេចន៍ទាំងឡាយណាដែលបានប្រើប្រាស់ក្នុងឯកសារអាជ្ញាប័ណ្ណនេះ ឬ ផ្នែកណាមួយរបស់ឯកសារនេះ និងនៅក្នុងឧបសម្ព័ន្ធភ្ជាប់ ប្រសិនបើពុំមានការបញ្ជាក់ខ្លឹមសារផ្សេងទេ ត្រូវមានន័យដូចខាងក្រោម : | In this or any of the following Parts of this document and in the Schedules below, unless otherwise specified or the context otherwise requires: |
| **"ថាមពលសកម្ម"** មានន័យថា ថាមពលដែលផលិត លំហូរ ឬផ្គត់ផ្គង់ដោយសៀគ្វីអគ្គិសនីមួយក្នុងរយៈពេលកំណត់ (ដែលជាផលគុណនៃពេល និងអានុភាពខណៈ) ដែលវាស់តាមខ្នាតវ៉ាត់ម៉ោង (Wh) និងមានខ្នាតគុណ ដូច្នេះ: 1,000 Wh = 1 Kilowatt-hour (kWh) 1,000 kWh = 1 Megawatt-hour (MWh). 1,000 MWh = 1 Gigawatt-hour (GWh) 1,000 GWh = 1 Terawatt-hour (TWh). | **"Active Energy"** means the electrical energy produced, flowing in or supplied by an electric circuit during a time interval, (being integral with respect to time of the instantaneous power), measured in units of watt-hours (Wh) and standard multiples thereof, that is: 1,000 Wh = 1 Kilowatt-hour (kWh) 1,000 kWh = 1 megawatt-hour (MWh). 1,000 MWh = 1 gigawatt-hour (GWh) 1,000 GWh = 1 terawatt-hour (TWh). |
| **"សវនកម្ម"** មានន័យថា ការជំរះបញ្ជីលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកកាន់អាជ្ញាប័ណ្ណដោយសវនករមួយ ក្នុងពេលធ្វើអាជីវកម្ម ។ | **"Audit"** means audit on the licensee's financial statement of financial year by an auditor. |
| **"អនុញ្ញាត"** ពាក់ព័ន្ធនឹងអាជីវកម្ម ឬសកម្មភាព មានន័យថា ការអនុញ្ញាតដែលមានចែងក្នុងអាជ្ញាប័ណ្ណនេះ ស្របតាមច្បាប់អគ្គិសនី ។ | **"Authorized"** in relation to any business or activity means Authorized by license granted under the Electricity Law. |
| **"លក្ខខណ្ឌ"** មានន័យថាលក្ខខណ្ឌចែងក្នុងអាជ្ញាប័ណ្ណនេះ ។ | **"Condition"** means a Condition set out in this License. |
| **"ថ្លៃភ្ជាប់ប្រព័ន្ធ"** មានន័យថា បន្ទុកត្រូវបង់ថ្លៃចំណាយសម្រាប់ការអនុវត្តន៍ការងារ ការផ្តល់ និងការតម្លើងរោងចក្រអគ្គិសនី ខ្សែបណ្តាញអគ្គិសនី និងនាឡិកាស្ទង់ក្នុងការសាងសង់ ឬការកែសម្រួលចំណុច ដែលត្រូវភ្ជាប់ចូល និងភ្ជាប់ចេញនៃប្រព័ន្ធចែកចាយអគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណ ដើម្បីផ្គត់ផ្គង់អគ្គិសនីឱ្យអតិថិជន ។ | **"Connection charges"** means charges made for carrying out works and provision and installation of electrical plant, electric lines and meters in constructing or modifying entry and exit points on the Licensee's Distribution System to give supply to a consumer. |
| **"អ្នកប្រើប្រាស់"** មានន័យថា បុគ្គលណាមួយ ឬអ្នកទទួលសិទ្ធិបន្តដែលទិញឬទទួលអគ្គិសនីដើម្បីប្រើប្រាស់ និងមិនមែនដើម្បីផ្តល់ ឬលក់បន្តឱ្យអ្នកដទៃទៀតឡើយ ។ | **"Consumer"** means a person or his authorized representative that purchases or receives electricity for consumption and not for delivery or resale to others. |
| **"អ្នកប្រើប្រាស់តូច"** គឺអ្នកប្រើប្រាស់ដែលទទួលការផ្គត់ផ្គង់ពីខ្សែបណ្តាញសាធារណៈតង់ស្យុងទាប ២៣០វ៉ុល ១ហ្វា និងត្រូវការកម្លាំងរហូតដល់ ៦០អំពែរ ឬ ៤០០វ៉ុល ៣ហ្វា និងត្រូវការកម្លាំងរហូតដល់ ៩០អំពែរ ។ | **"Small Consumers"** mean a consumer requiring power up to 60 amperes at single phase 230 volts or up to 90 amperes at three phase 400 volts is categorized as Small Consumer. Small Consumers will be supplied power from the public LV network. |

| | |
|---|---|
| **"អ្នកប្រើប្រាស់ធុនមធ្យម"** គឺអ្នកប្រើប្រាស់ ដែលទទួលការផ្គត់ផ្គង់ពីបន្ទប់ភ្លើង MV/LV តាមទ្វារចរន្តតង់ស្យុងទាបដាច់ដោយឡែក ៤០០វ៉ុល ៣ហ្វា និងមានកម្លាំងលើសពី ៩០អំពែរ រហូតដល់តិចជាង ១៥០អំពែរ។ នាឡិកាស្ទង់ត្រូវតម្លើងនៅលើទ្វារចរន្ត នៅក្នុងបន្ទប់ភ្លើងនោះ។ | **"Medium Consumers"** mean a consumer requiring power more than 90 amperes and less than 150 amperes at three phase 400 volts is categorized as Medium Consumer. Medium Consumers will be supplied power through a separate LV feeder from the MV/LV substation. The meter will be installed at the substation on this feeder. |
| **"អ្នកប្រើប្រាស់ធុនធំ"** គឺអ្នកប្រើប្រាស់ដែលទទួលការផ្គត់ផ្គង់ជាទូទៅ ពីបន្ទប់ភ្លើង MV/LV ដាច់ដោយឡែក នៅក្នុងទីតាំងរបស់អ្នកប្រើប្រាស់ តាមតង់ស្យុង ៤០០វ៉ុល ៣ហ្វារ និងត្រូវការកម្លាំងលើសពី ១៥០អំពែរ រហូតដល់តិចជាង ៤០០អំពែរ ។ ក្នុងករណីខ្លះ បើអ្នកផ្គត់ផ្គង់ពិនិត្យឃើញថាអាចអនុវត្តបានសម្រាប់អ្នកប្រើប្រាស់ដែលប្រើប្រាស់អនុភាពមួយផ្នែកនៃបន្ទប់ភ្លើង ការផ្គត់ផ្គង់អាចបន្តចេញតាមខ្សែតង់ស្យុងទាបដាច់ដោយឡែក ពីបន្ទប់ភ្លើងសាធារណៈ ។ នាឡិកាស្ទង់ត្រូវតម្លើងនៅលើទ្វារចរន្ត នៅបន្ទប់ភ្លើងនោះ។ | **"Big Consumers"** mean a consumer requiring power more than 150 amperes and less than 400 amperes at three phase 400 volts is categorized as Big Consumer. Big Consumers will be supplied power generally from a separate MV/LV substation on their premises. The meter will be installed indoors or close to the substation. In some cases, if found feasible by the licensee, the supply to Big Consumers can be given by partly utilizing the capacity of a public MV/LV substation through a separate LV feeder. The meter will be installed at the substation on this feeder. |
| **"អ្នកប្រើប្រាស់តង់ស្យុងមធ្យម"** គឺអ្នកប្រើប្រាស់ដែលទទួលការផ្គត់ផ្គង់អគ្គិសនីតង់ស្យុងមធ្យមពីបណ្តាញតង់ស្យុងមធ្យម និងមានតម្រូវការអនុភាពមិនតិចជាង 275kVA ។ នាឡិកាស្ទង់តង់ស្យុងមធ្យម ត្រូវតម្លើងនៅលើបណ្តាញតង់ស្យុងមធ្យមផ្ទាល់។ | **"MV Consumers"** mean a consumer requiring power more than 275kVA will be supplied power at MV by a direct connection from the MV network. MV metering will be provide on the MV connection |
| **"អ្នកប្រើប្រាស់ដុំ"** គឺអ្នកប្រើប្រាស់ទាំងឡាយណា ដែលទទួលការផ្គត់ផ្គង់អគ្គិសនីតាមតង់ស្យុងខ្ពស់ (លើសពី ៣៥,០០០ វ៉ុល)។ | **"Bulk Consumers"** mean a consumer supplied power at high voltage (above 35.000 Volts). |
| **"អតិថិជន"** មានន័យថា បុគ្គលណាមួយដែលបានទទួលការផ្គត់ផ្គង់ ឬទាមទារឱ្យមានការផ្គត់ផ្គង់អគ្គិសនីឱ្យទីតាំងខ្លួនក្នុងតំបន់អនុញ្ញាត ។ | **"Customer"** means any person supplied or requiring to be supplied with electricity either for own consumption or for delivery or sales to others. |
| **"អាជីវកម្មចែកចាយ"** មានន័យថា ការធ្វើអាជីវកម្មរបស់អ្នកកាន់អាជ្ញា-ប័ណ្ណចែកចាយមានលក្ខណៈជា:<br>(ក)-ការចែកចាយអគ្គិសនីតាមរយៈប្រព័ន្ធចែកចាយរបស់អ្នកកាន់អាជ្ញាប័ណ្ណគិតរួមទាំងអាជីវកម្មក្នុងការផ្គត់ផ្គង់ការតភ្ជាប់ប្រព័ន្ធជាមួយប្រព័ន្ធនេះ<br>(ខ)-ការផ្តល់សេវាសម្រាប់នាឡិកាស្ទង់ និង<br>(គ)-ការផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់ ។ | **"Distribution Business"** means the business of the Distribution Licensee including a business ancillary to:<br>(a) the distribution of electricity through the Licensee's Distribution System, including any business in providing connections to such system;<br>(b) the provision of Metering Services; and<br>(c) the supply of electricity to consumers. |
| **"កូដប្រព័ន្ធចែកចាយ"** ជាក្បួនច្បាប់ដែលគ្របដណ្តប់លើទិដ្ឋភាពបច្ចេកទេសធំៗទាំងអស់ដែលពាក់ព័ន្ធជាមួយការតភ្ជាប់ ការ | **"Distribution Code"** means the Distribution Code covering all material technical aspects relating to |

| | | | |
|---|---|---|---|
| | ដំណើរការ និងការប្រើប្រាស់ប្រព័ន្ធចែកចាយរបស់អ្នកកាន់អាជ្ញាប័ណ្ណ ឬការដំណើរការខ្សែបណ្តាញ និងបរិក្ខាអគ្គិសនី ដែលបានតភ្ជាប់ជាមួយប្រព័ន្ធចែកចាយរបស់អ្នកកាន់អាជ្ញាប័ណ្ណ ឬរបស់បុគ្គលណាមួយផ្សេងទៀត ដែលបានទទួលការអនុញ្ញាតឱ្យតភ្ជាប់ជាមួយប្រព័ន្ធរបស់អ្នកកាន់អាជ្ញាប័ណ្ណ ។ | | connections to and the operation and use of the Licensee's Distribution System and the operation of electric lines and electrical plant connected to the Distribution System of the Licensee or distribution system of any other person authorized to connect with Licensee's system. |
| **"អាជ្ញាប័ណ្ណចែកចាយ"** | មានន័យថា អាជ្ញាប័ណ្ណចែកចាយដែលបានផ្តល់ក្នុងប្រការ១ នៃផ្នែកទី ១ ។ | **"Distribution License"** | means the Distribution License granted in Article 1 of Part I. |
| **"ប្រព័ន្ធចែកចាយ"** | មានន័យថា ខ្សែបណ្តាញអគ្គិសនីទាំងអស់របស់អ្នកកាន់អាជ្ញាប័ណ្ណក្នុងតំបន់ចែកចាយដែលបានអនុញ្ញាត និងខ្សែបណ្តាញអគ្គិសនីណាមួយផ្សេងទៀត ដែលអាជ្ញាធរអគ្គិសនីកម្ពុជាអាចបញ្ជាក់ថា ជាផ្នែកនៃប្រព័ន្ធចែកចាយរបស់អ្នកកាន់អាជ្ញាប័ណ្ណ ព្រមទាំងនាឡិកាស្ទង់ និងបរិក្ខាអគ្គិសនីណាមួយរបស់អ្នកកាន់អាជ្ញាប័ណ្ណដែលបានប្រើប្រាស់សម្រាប់ចែកចាយអគ្គិសនី ដោយអ្នកកាន់អាជ្ញាប័ណ្ណ ដោយឡែកចំពោះអ្នកចែកចាយដទៃណាមួយផ្សេងទៀត វាមានអត្ថន័យដូចគ្នា ដូចមានចែងក្នុងអាជ្ញាប័ណ្ណដែលបានកាន់ដោយអ្នកកាន់អាជ្ញាប័ណ្ណចែកចាយនោះ ។ | **"Distribution System"** | Means all electric lines of the Licensee within the Licensee's authorized distribution area and any other electric lines which EAC may specify as forming part of the Licensee's Distribution System, and includes any electrical plant and meters of the Licensee which are used in connection with the distribution of electricity by the Licensee; and, in relation to any other distributor, it shall have the same meaning as it has in the license held by such distributor. |
| **"អ្នកចែកចាយ"** | មានន័យថាបុគ្គលណាមួយ ដែលបានកាន់អាជ្ញាប័ណ្ណចែកចាយ ។ | **"Distributor"** | means any person who holds a Distribution License. |
| **"អាជ្ញាធរអគ្គិសនីកម្ពុជា"** | មានន័យថា អាជ្ញាធរដែលបានបង្កើតឡើងដោយច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០២០១/០៣ ។ | **"EAC"** | means the Electricity Authority of Cambodia established by the Electricity Law promulgated by Royal Decree No. NS/RKM/0201/03. |
| **"អគ្គិសនីកម្ពុជា"** | មានន័ថា ក្រុមហ៊ុនអគ្គិសនីកម្ពុជាដែលបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខនស/រកត/០៣៩៦/១០ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៩៦ ។ | **"EDC"** | means the Electricité du Cambodge, established by Royal Decree No. ChS/RKT/0396/10 dated March 09, 1996. |
| **"ច្បាប់អគ្គិសនី"** | មានន័យថា ច្បាប់អគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ។ | **"Electricity Law"** | means the Electricity Law of the Kingdom of Cambodia, promulgated by the Royal Decree No. NS/RKM/0201/03 dated 2 February 2001. |
| **"កូដប្រព័ន្ធបញ្ជូន"** | ជាក្បួនច្បាប់ ដែលគ្របដណ្តប់លើសកម្មភាពទាំងអស់ ដែលពាក់ព័ន្ធជាមួយការតភ្ជាប់ការដំណើរការ និងការប្រើប្រាស់ប្រព័ន្ធបញ្ជូន រួមមានការដំណើការខ្សែបណ្តាញ និងរោងចក្រផលិតអគ្គិសនីដែលភ្ជាប់នឹងប្រព័ន្ធបញ្ជូននោះ។ | **"Grid Code"** | means the code covering all activities relating to the connections, operation and use of Transmission System, including the operation of electric lines and electrical plant connected to the Transmission System. |
| **"ឯកសារអាជ្ញាប័ណ្ណ"** | មានន័យថា ឯកសារនេះដែលមានពីផ្នែកទី១ ដល់ផ្នែកទី២ និងឧបសម្ព័ន្ធទី១ ដល់ឧបសម្ព័ន្ធទី៤។ | **"License"** | means this document comprising Parts 1, Part 2 and Schedules 1 to 4 of this License. |

| | |
|---|---|
| **“អ្នកកាន់អាជ្ញាប័ណ្ណ”** មានន័យថា សហគ្រាស **អេឡិក ទ្រីស៊ីធី ត្បូងឃ្មុំ** ។ | **“Licensee”** means **Electricity Tbong Khmum Enterprise.** |
| **“នាឡិកាស្ទង់”** រួមមាននាឡិកាស្ទង់ និងបរិក្ខាពាក់ព័ន្ធដទៃទៀត ដែលមានឥទ្ធិពលផ្ទាល់លើការដំណើរការនាឡិកាស្ទង់នោះ ។ | **“Meter”** includes any meter and associated equipment, which materially affects the operation of that meter. |
| **“ការជូនដំណឹង”** មានន័យថា (ប្រសិនបើពុំមានការបញ្ជាក់ផ្សេងទៀត) ការជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬដោយមធ្យោបាយសមស្របណាមួយផ្សេងទៀត ។ | **“Notice”** means (unless otherwise specified) notice given in writing or by any other reasonable means. |
| **“ការបញ្ជាក់”** រួមមានការបដិសេធ ឬការសំណូមពរណាមួយដែលបានធ្វើជាលាយលក្ខណ៍អក្សរ ។ | **“Representation”** includes any objection or any other proposal made in writing. |
| **“មធ្យោបាយរងបញ្ជូនអគ្គិសនី”** មានន័យថា ជាប្រព័ន្ធដែលរួមមានផ្នែកសំខាន់ៗនៃខ្សែបណ្តាញតង់ស្យុងមធ្យម ប្រព័ន្ធត្រួតពិនិត្យ ប្រព័ន្ធការពារ និងប្រព័ន្ធនាឡិកាស្ទង់ ដែលជាកម្មសិទ្ធ និងដំណើការដោយអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូន ហើយប្រើប្រាស់សម្រាប់ផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកកាន់អាជ្ញាប័ណ្ណដទៃទៀត ឬអ្នកប្រើប្រាស់តង់ស្យុងមធ្យម ។ | **“Sub-Transmission Facility”** means the system consisting mainly of medium voltage electric lines and associated control, protection and metering facility owned or operated by transmission licensees and used for supply of electricity to other licensees or MV consumers. |
| **“កិច្ចព្រមព្រៀងផ្គត់ផ្គង់”** មានន័យថា កិច្ចព្រមព្រៀងរវាងអ្នកកាន់អាជ្ញាប័ណ្ណ និងអ្នកប្រើប្រាស់តង់ស្យុងមធ្យម ឬអ្នក កាន់អាជ្ញាប័ណ្ណមួយផ្សេងទៀត សម្រាប់ការលក់អគ្គិសនី ។ | **“Supply Agreement”** means the agreement between the Licensee and the MV Consumer or another licensee for sale of electricity. |
| **“កិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី”** មានន័យថាកិច្ចព្រមព្រៀងរវាងអ្នកកាន់អាជ្ញាប័ណ្ណណាមួយ និងអ្នកប្រើប្រាស់ដែលប្រើប្រាស់ប្រព័ន្ធបញ្ជូនរងរបស់ខ្លួនសម្រាប់ផ្តល់សេវា និងធ្វើឱ្យមានសេវាកម្មបញ្ជូន ហើយបានទទួលការយល់ព្រមពីអាជ្ញាធរអគ្គិសនីកម្ពុជា ។ | **“Transmission/Wheeling Agreement”** means the agreement between the Licensee and the user of its Sub-transmission System for providing and availing the transmission/wheeling service and approved by EAC. |
| **“អាជីវកម្មបញ្ជូនអគ្គិសនី”** មានន័យថាជាអាជីវកម្មដោយមានការអនុញ្ញាតរបស់អ្នកកាន់អាជ្ញាប័ណ្ណក្នុងការធ្វើផែនការ ការអភិវឌ្ឍន៍ ការសាងសង់ ការដំណើការ និងការថែទាំប្រព័ន្ធបញ្ជូនរបស់អ្នកកាន់អាជ្ញាប័ណ្ណ ដោយរួមទាំងអាជីវកម្មណាមួយដែលមានទំនាក់ទំនងនឹងប្រព័ន្ធបញ្ជូននេះផង ។ | **“Transmission Business”** means the authorized business of the Licensee in the planning, development, construction, operation and maintenance of its Transmission System, including any business in providing connections to its Transmission System. |
| **“មធ្យោបាយបញ្ជូនអគ្គិសនី”** មានន័យថាជាមធ្យោបាយសំខាន់ៗរួមមានខ្សែបណ្តាញអគ្គិសនីតង់ស្យុងខ្ពស់ ជា | **“Transmission Facility”** means the facility consisting mainly |

កម្មសិទ្ធិ ឬដំណើរការដោយអ្នកកាន់អាជ្ញាប័ណ្ណច្រើន និងប្រើប្រាស់សម្រាប់បញ្ជូនអគ្គិសនីពីរោងចក្រអគ្គិសនីមួយទៅអនុស្ថានីយមួយ ឬទៅរោងចក្រអគ្គិសនីមួយទៀត ឬរវាងអនុស្ថានីយ និងអនុស្ថានីយ ឬទៅ ឬមក ពីប្រព័ន្ធភ្ជាប់ពីខាងក្រៅណាមួយ ហើយរួមមានអនុស្ថានីយតង់ស្យុងខ្ពស់/តង់ស្យុងមធ្យម រោងចក្រណាមួយ និងបរិក្ខាផ្សេងៗ និងប្រព័ន្ធត្រួតពិនិត្យ ប្រព័ន្ធការពារ ប្រព័ន្ធនាឡិកាស្ទង់ និងមធ្យោបាយគមនាគមន៍ដែលជាកម្មសិទ្ធិ និងដំណើរការដោយអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូន ក្នុងការភ្ជាប់ជាមួយខ្សែបណ្តាញបញ្ជូនល្អត្រឹមត្រូវមួយរហូតដល់ចំណុចតភ្ជាប់នៃប្រព័ន្ធនេះជាមួយប្រព័ន្ធរងបញ្ជូន ឬប្រព័ន្ធចែកចាយ ។

of high voltage electric lines owned or operated by the Licensees and used for the transmission of electricity from one generating station to a substation or to another generating station or between substations or to or from any external interconnection and includes the HV/MV substation, any plant and apparatus and associated control, protection, metering and communication facilities owned and operated by transmission licensees in connection with proper transmission of electricity up to the interconnection with the Sub-transmission system or distribution System.

**"អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូន"** មានន័យថា ជាបុគ្គល/នីតិបុគ្គលដែលកាន់អាជ្ញាប័ណ្ណបញ្ជូន ។

**"Transmission Licensee"** means a person/a company who holds a Transmission License.

**"ប្រព័ន្ធបញ្ជូន"** មានន័យថា ជាប្រព័ន្ធដែលរួមមានមធ្យោបាយបញ្ជូនអគ្គិសនី និងមធ្យោបាយរងបញ្ជូនអគ្គិសនី ។

**"Transmission System"** means the system consisting of the Transmission Facilities and Sub-Transmission facilities.

## ២ ភារកិច្ចទូទៅរបស់អ្នកកាន់អាជ្ញាប័ណ្ណ

## 2-GENERAL OBLIGATION OF LICENSEE

### លក្ខខណ្ឌទី១: ភារកិច្ចគោរពច្បាប់ អនុក្រឹត្យ បទបញ្ជា និងកិច្ចព្រមព្រៀងបញ្ជូន

១- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវគោរពតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យ បទបញ្ញត្តិដែលពាក់ព័ន្ធជាមួយច្បាប់ និងល័ក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណ ។

២- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវគោរពតាមបទបញ្ជា សេចក្តីណែនាំ និងសេចក្តីសម្រេចអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា ដោយអនុលោមតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងល័ក្ខខ័ណ្ឌអាជ្ញាប័ណ្ណនេះ ។

៣- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវគោរពតាមភារកិច្ចបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និងអនុក្រឹត្យនានាពាក់ព័ន្ធនឹងការការពារបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា ។

### Condition 1: Obligation on compliance with the Laws, Sub-Decrees, Orders and Wheeling Agreement

1. The Licensee shall comply with the Electricity Law and all other applicable Laws and Sub Decrees, Regulations issued under these Laws and the Conditions of License.

2. The Licensee shall comply with any orders, directions and determinations made by EAC pursuant to the electricity Law and this License.

3. The Licensee is subjected to the environmental obligations as specified in the Law on Environmental Protection promulgated by the Royal Decree NS/RKM/1296/36, dated 24/12/1996 and Other Sub-Decrees on Environmental Protection of the Kingdom of Cambodia.

### លក្ខខណ្ឌទី២: ភារកិច្ចគោរពតាមស្តង់ដាបច្ចេកទេស សុវត្ថិភាព និងបរិស្ថាន

### Condition 2: Obligation on compliance with technical standard, Safety and Environment

| | |
|---|---|
| ១- អ្នកកាន់អាជ្ញាប័ណ្ណត្រូវគោរពតាមស្តង់ដា ទាក់ទងទៅនឹងកិច្ចប្រតិបត្តិការ បច្ចេកទេស សុវត្ថិភាព និងបរិស្ថានដែលបង្កើតឡើង និងផ្សព្វផ្សាយ ដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ | 1. The Licensee shall comply with the standards on technical operation, safety and environment, issued and published by Ministry of Industry, Mines and Energy. |
| **លក្ខខណ្ឌទី៣: លក្ខខណ្ឌចំពោះការធ្វើអាជីវកម្ម** | **Condition 3: Conditions on the Business** |
| ១- អ្នកកាន់អាជ្ញាប័ណ្ណត្រូវដំណើរការ និងគ្រប់គ្រងសេវាកម្មអគ្គិសនីដែលផ្តល់ដោយអាជ្ញាប័ណ្ណនេះ ឱ្យមានប្រសិទ្ធភាព គុណភាព និងតម្លាភាព ដោយអនុលោមតាមល័ក្ខខ័ណ្ឌកំណត់ក្នុងអាជ្ញាប័ណ្ណនេះ និងបទប្បញ្ញត្តិដែលចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។ | 1. The Licensee shall operate and manage the Services provided under this License in an efficient, qualitative and transparent manner in accordance with the requirement of this License and the Regulations issued by EAC. |
| ២- អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវមានភាគហ៊ុន ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយដែលអាជ្ញាប័ណ្ណមិនអនុញ្ញាតមានដូចជា អាជីវកម្ម ផលិតកម្ម អាជីវកម្មបញ្ជូន អាជីវកម្មចែកចាយ ឬផ្គត់ផ្គង់ថាមពល ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។ | 2. The licensee shall not acquire or associate itself with any additional business, which is not permitted by this License, including the business of generation, transmission, distribution or supply of energy, without the prior approval in writing of EAC. |
| ៣- អ្នកកាន់អាជ្ញាប័ណ្ណ មិនត្រូវប្រើប្រាស់អចលនទ្រព្យនៃអាជីវកម្មរបស់អាជ្ញាប័ណ្ណនេះសម្រាប់គោលបំណងអ្វីក្រៅពីអាជីវកម្មដែលបានអនុញ្ញាត ដូចកំណត់ក្នុងឯកសារនេះ ដោយពុំមានការអនុម័តជាមុនពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។ | 3. The Licensee shall not use the assets of this License's business for the purpose other than the purpose specified in Article 1, Part 1of this License without prior written approval of EAC. |
| ៤- អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវចុះកិច្ចព្រមព្រៀងជាមួយភាគីទី៣ ដើម្បីទិញអគ្គិសនីដោយគ្មានការអនុម័តជាមុនពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។ | 4. The Licensee shall not enter into any arrangements with third party for purchase of electricity without prior approval of EAC. |
| ៥- អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវចុះកិច្ចព្រមព្រៀងថ្មីណាមួយ ឬកែសម្រួលខ្លឹមសារនៃកិច្ចព្រមព្រៀង សម្រាប់បញ្ជូនអគ្គិសនី ឬលក់ដុំអគ្គិសនីទៅឱ្យអ្នកកាន់អាជ្ញាប័ណ្ណ ដោយពុំមានការអនុម័តជាមុនពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។ | 5. The Licensee shall not enter into any new agreement or revise an existing agreement for wheeling of energy or bulk sale to other licensees without prior approval of EAC. |
| ៦- នៅគ្រប់ពេល អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវប្រគល់អាជ្ញាប័ណ្ណ ឬផ្ទេរការកាន់កាប់របស់ខ្លួន ឬផ្នែកណាមួយរបស់វា ដោយលក់ បញ្ចាំ ជួល ប្តូរ ឬផ្សេងពីនេះ លើកលែងតែមានកំណត់ក្នុងកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី និង/ឬអនុម័តពីអាជ្ញាធរអគ្គិសនីកម្ពុជា ។ | 6. The Licensee shall not, at any time, assign this License or transfer its undertaking, or any part thereof, by sale, mortgage, lease, exchange or otherwise, unless approved by EAC. |
| ៧- អ្នកមានភាគហ៊ុនជាមួយអ្នកកាន់អាជ្ញាប័ណ្ណនេះ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ៣ មិនត្រូវមានភាគហ៊ុន ឬមានអត្ថប្រយោជន៍ហិរញ្ញវត្ថុផ្ទាល់ជាមួយអ្នកកាន់អាជ្ញាប័ណ្ណផ្សេងទៀត ដោយគ្មានការអនុម័តពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។ | 7. The shareholders of the Licensee, defined in Schedule 4, shall not own the shares in or have any other direct financial interest in any other licensee without prior approval of EAC. |
| ៨- កិច្ចព្រមព្រៀងណាមួយពាក់ព័ន្ធជាមួយកិច្ចការ ដែលបានអធិប្បាយក្នុងវាក្យខ័ណ្ឌទី១, ២, ៣, ៤, ៥, ៦ និង ៧ ខាងលើ បើពុំមានការឯកភាព ជាលាយលក្ខណ៍អក្សរជាមុនពីអាជ្ញាធរអគ្គិសនីកម្ពុជាទេ ត្រូវចាត់ទុកថាជាមោឃៈ និងត្រូវទុកជាការរំលោភលើល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណ ។ | 8. Any agreement relating to any transaction of the nature described above at paragraph 2, 3, 4, 5, 6 and 7, unless made with the prior written consent of EAC, shall be void and would constitute violation of Conditions of this License. |
| **លក្ខខណ្ឌទី៤ : ភារកិច្ចធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សកម្មភាពសេវាកម្មរបស់ខ្លួន តាមការកំណត់របស់អាជ្ញាធរអគ្គិសនីកម្ពុជា** | **Condition4: Obligation on Financial statement and reports on electric power service required by EAC** |
| ១- ឆ្នាំការិយបរិច្ឆេទនៃអ្នកកាន់អាជ្ញាប័ណ្ណ ត្រូវចាប់គិតពីថ្ងៃទី១ ខែមករា | 1. The financial year of the Licensee shall be reckoned every year |

រហូតដល់ថ្ងៃទី៣១ ខែធ្នូ រៀងរាល់ឆ្នាំ ។

២- អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជា នូវច្បាប់ចម្លងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច មិនលើសពី៣ខែ ក្រោយពីបញ្ចប់ឆ្នាំការិយបរិច្ឆេទដែលរបាយការណ៍នោះពាក់ព័ន្ធ ។ ការធ្វើសវនកម្មអាចជំនួសដោយការត្រួតពិនិត្យរបស់អាជ្ញាធរ ក្នុងករណីដែលសភាពការណ៍ជាក់ស្តែងតម្រូវ ។

៣- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្តល់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជានូវបណ្តាព័ត៌មានទាំងឡាយ ដែលអាជ្ញាធរទាមទារជាបន្តបន្ទាប់ តាមបែបបទ និងទំរង់កំណត់ដោយអាជ្ញាធរ ដើម្បីអាចឱ្យអាជ្ញាធរផ្ទៀងផ្ទាត់មើលការអនុវត្តន៍របស់អ្នកកាន់អាជ្ញាប័ណ្ណ តាមល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ និងតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងបទប្បញ្ញត្តិផ្សេងៗទៀត ។

៤- ដោយមិនគិតពីភាពទូទៅនៃវាក្យខ័ណ្ឌទី៣ អាជ្ញាធរអគ្គិសនីកម្ពុជា អាចទាមទារឱ្យអ្នកកាន់អាជ្ញាប័ណ្ណផ្តល់នូវព័ត៌មានណាមួយ ឱ្យមានលក្ខណៈលំអិតខ្លាំងជាង ឬខុសពីការផ្តល់ព័ត៌មានធម្មតាដល់អាជ្ញាធរអគ្គិសនីកម្ពុជា ។

**ល័ក្ខខ័ណ្ឌទី៥ : ភាតព្វកិច្ចបង់កម្រៃអាជ្ញាប័ណ្ណ**

១- ចាប់ពីថ្ងៃចូលជាធរមានរហូតដល់ថ្ងៃបញ្ចប់អាណត្តិនៃអាជ្ញាប័ណ្ណនេះ អ្នកកាន់អាជ្ញាប័ណ្ណត្រូវបង់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជានូវ **កម្រៃអាជ្ញាប័ណ្ណប្រចាំខែ** តាមអត្រាកម្រៃអាជ្ញាប័ណ្ណ និងរូបមន្តគណនាកម្រៃអាជ្ញាប័ណ្ណ ដែលត្រូវកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា សម្រាប់ឆ្នាំការិយបរិច្ឆេទនីមួយៗ ដោយអនុលោមតាមមាត្រា២៧ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣នៃអនុក្រឹត្យស្តីពីការកំណត់កំរិតអតិបរមានៃកម្រៃអាជ្ញាប័ណ្ណ សម្រាប់អនុវត្តចំពោះអ្នកធ្វើសេវាកម្មអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- វិក្កយបត្រនៃកម្រៃអាជ្ញាប័ណ្ណប្រចាំខែ ត្រូវចាត់ទុកថាជំពាក់ និងត្រូវបង់ក្នុងរយៈពេល១៤ថ្ងៃ បន្ទាប់ពីថ្ងៃដែលអ្នកកាន់អាជ្ញាប័ណ្ណបានទទួលវិក័យប័ត្រ ។

**ល័ក្ខខ័ណ្ឌទី៦ : សុខុមាលភាព និងសុវត្ថិភាពនៃនិយោជិត**

១- អ្នកកាន់អាជ្ញាប័ណ្ណត្រូវពិភាក្សាជាមួយនិយោជិតរបស់ខ្លួន ដើម្បីរកហេតុផល ធ្វើយ៉ាងណាឱ្យនិយោជិតបម្រើការនោះមានសុខុមាលភាព និងសុវត្ថិភាព ។

**ល័ក្ខខ័ណ្ឌទី៧ : ការទំនាក់ទំនង**

១- រាល់ទំនាក់ទំនងទាំងអស់ពាក់ព័ន្ធជាមួយអាជ្ញាប័ណ្ណនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយយកភាសាខ្មែរជាគោល ។

**ល័ក្ខខ័ណ្ឌទី៨:ល័ក្ខខ័ណ្ឌលក់មធ្យោបាយចែកចាយ និងមធ្យោបាយបញ្ជូនរងអគ្គិសនី ក្នុងករណីមានការតំរូវពីអាជ្ញាធរអគ្គិសនីកម្ពុជា**

from 1st January to the following 31st December.

2. The Licensee shall submit to EAC the copy of its audited financial statement not later than 3 months after the end of financial year to which they relate. The audit can be replaced by the control of EAC in the case that actual situation requires.

3. The Licensee shall provide, in the manner and form and at time determined by EAC, such information as EAC may require from time to time for monitoring the Licensee's compliance with the conditions of this license, provisions of the electricity law and any other legislative or regulatory requirements.

4. Without prejudice to the generality of paragraph 3, EAC may require the Licensee to supply information which is more extensive than or differs from that required to be prepared and supplied to EAC.

**Condition5: Obligation on payment of license fee**

1. From the effective date to end of the term of license, the Licensee shall pay to EAC **"the monthly license fee"** which is calculated according to the rate of license fee and the formula determined by EAC for each financial years pursuant to Article 27 of the Law and Article 3 of Sub-Decree of the Royal Government of Cambodia fixing the maximum License fee for the electric power services in the Kingdom of Cambodia.

2. Each invoice of monthly license fee shall be due and payable within 14 days after the day on which Licensee receives it.

**Condition 6: Health and Safety of Employees**

1. The Licensee shall consult with persons employed by it in order to consider the matters of the health and safety of such persons.

**Condition 7: Communication**

1. All communications relating to this License shall be written in Khmer as official.

**Condition 8: Sale Condition of distribution and sub transmission facility in the case it is the required from EAC**

១- ក្នុងរយៈពេល ៦ ខែ បន្ទាប់ពីបានទទួលអាជ្ញាប័ណ្ណនេះ អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវស្នើសុំអាជ្ញាធរអគ្គិសនីកម្ពុជាអនុម័ត និងចុះបញ្ជីអចលនទ្រព្យសម្រាប់ធ្វើសេវាកម្មរបស់ខ្លួន។ បញ្ជីនេះត្រូវបញ្ជាក់លម្អិតនៅឆ្នាំចាប់ផ្តើមដំណើរការអាជីវកម្ម និងតម្លៃដើមនៃមធ្យោបាយធ្វើសេវាកម្មនីមួយៗ ។ បន្ទាប់ពីនោះ នៅរៀងរាល់ឆ្នាំ មុនថ្ងៃទី១៥ ខែកុម្ភៈ អ្នកកាន់អាជ្ញាប័ណ្ណត្រូវស្នើសុំអាជ្ញាធរអគ្គិសនីកម្ពុជាកែសម្រួលបញ្ជីមធ្យោបាយធ្វើសេវាកម្មរបស់ខ្លួន ដែលមានជាក់ស្តែងដល់ថ្ងៃទី៣១ ខែធ្នូ កន្លងមក។ បញ្ជីនេះត្រូវ បង្ហាញនូវមធ្យោបាយធ្វើសេវាកម្មដែលមានពីដើមឆ្នាំ ដែលបានបន្ថែម ឬលុបចេញក្នុងឆ្នាំដោយមានបញ្ជាក់តំលៃមធ្យោបាយធ្វើសេវាកម្មនោះ និងមធ្យោបាយធ្វើសេវាកម្មដែលមាននៅចុងឆ្នាំ ។

1. Within six months after receiving this license, the licensee shall submit the list of its facilities for approval and registering at EAC as relevant asset. The list should also give details on year of commissioning and the original cost of each facility. Thereafter, for revision of the list of relevant asset, the licensee shall submit to EAC by 15th February each year, the list of its facilities as on 31st December of the previous year. The list should indicate the facilities in the beginning of the year, additions made during the year with its cost, deletion made during the year with its original cost and facilities at the end of the year.

២- ស្របតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យនានា ក្នុងករណីដកហូតអាជ្ញាប័ណ្ណទាំងមូល ឬមួយផ្នែក អាជ្ញាធរអគ្គិសនីកម្ពុជាអាចតម្រូវឱ្យអ្នកកាន់អាជ្ញាប័ណ្ណលក់ ឬផ្ទេរមធ្យោបាយធ្វើសេវាកម្មដែលបានចុះបញ្ជីនៅអាជ្ញាធរអគ្គិសនីកម្ពុជា ឱ្យអ្នកបន្តវេនមួយផ្សេងទៀត តាមគោលការណ៍ហិរញ្ញវត្ថុ ដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា។

2. Under Electricity Law and Sub-decrees, in the case of revocation of license in full or part, EAC can require licensee to sale or transfer its facilities registered with EAC as relevant asset to the successor in accordance with financial principle determined by EAC.

## ៣. លក្ខខណ្ឌសេវាកម្មសម្រាប់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស

## 3-SERVICE CONDITIONS FOR SPECIAL PURPOSE TRANSMISSION LICENSE

### លក្ខខណ្ឌទី៩: លក្ខខណ្ឌចំពោះមធ្យោបាយបញ្ជូនអគ្គិសនី/មធ្យោបាយបញ្ជូនរងអគ្គិសនី

### Condition 9: Condition on Transmission/ Sub-Transmission Facilities

១- អាជ្ញាប័ណ្ណនេះ ផ្តល់សិទ្ធិឱ្យអ្នកកាន់អាជ្ញាប័ណ្ណមានសិទ្ធិធ្វើសេវាកម្មបញ្ជូនអគ្គិសនី ដោយដំណើរការប្រព័ន្ធបញ្ជូនអគ្គិសនី/ ប្រព័ន្ធបញ្ជូនរងអគ្គិសនីដែលមានកំណត់ច្បាស់លាស់ក្នុងឧបសម្ព័ន្ធ១ នៃអាជ្ញាប័ណ្ណនេះ ។ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមានបំណងបន្ថែមមធ្យោបាយបញ្ជូនអគ្គិសនី/មធ្យោបាយបញ្ជូនរងអគ្គិសនី អ្នកកាន់អាជ្ញាប័ណ្ណត្រូវស្នើសុំធ្វើវិសោធនកម្មអាជ្ញាប័ណ្ណដើម្បីបញ្ចូលមធ្យោបាយបញ្ជូនអគ្គិសនី/មធ្យោបាយបញ្ជូនរងអគ្គិសនីថ្មីនៅក្នុងអាជ្ញាប័ណ្ណនេះ ។

1. This License grants the right to the Licensee to provide transmission service by operating the specific Sub-Transmission Facilities specified in Schedule 1. If the Licensee intends to add new Transmission/ Sub-Transmission Facilities, then it must get the license amended to include the new facilities in the License.

២- អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់ប្រព័ន្ធនាឡិកាស្ទង់សមស្រប សម្រាប់វាស់បរិមាណថាមពលនាំចូល និងនាំចេញតាមមធ្យោបាយបញ្ជូនអគ្គិសនី/មធ្យោបាយបញ្ជូនរងអគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណ ។

2. The Licensee shall provide suitable Meters to measure electrical quantities imported and exported by the Sub-Transmission Facility of the Licensee.

### លក្ខខណ្ឌទី១០ : លក្ខខណ្ឌដំណើរការមធ្យោបាយបញ្ជូនរងអគ្គិសនី

### Condition 10: Condition on Operation of Sub-Transmission Facilities

១- នៅពេលមជ្ឈមណ្ឌលបញ្ជាប្រកាសឱ្យប្រើប្រាស់សេចក្តីណែនាំ អ្នកកាន់អាជ្ញាប័ណ្ណត្រូវដំណើរការមធ្យោបាយបញ្ជូនរងអគ្គិសនីរបស់ខ្លួនតាមការណែនាំនោះ, ក្នុងករណីពុំទាន់មាន អ្នកកាន់អាជ្ញាប័ណ្ណត្រូវគោរពតាមគោលការណ៍អនុវត្តរបស់ក្រុមហ៊ុនអគ្គិសនីដែលមានបទពិសោធន៍ល្អ។

1. The Licensee shall operate its Sub-transmission Facility as per instructions of the Control Center, when such instructions are issued, otherwise the Licensee shall follow best utility practices.

## លក្ខខណ្ឌទី១១ : លក្ខខណ្ឌចំពោះការបើកចំហសិទ្ធិប្រើប្រាស់ និងសិទ្ធិភ្ជាប់ជាមួយមធ្យោបាយមធ្យោបាយបញ្ជូនរង អគ្គិសនីដោយមិនរើសអើង

១- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវបើកចំហដោយគ្មានការរើសអើងឱ្យអ្នកកាន់អាជ្ញាប័ណ្ណផ្សេងទៀត និងអតិថិជនតង់ស្យុងមធ្យម ប្រើប្រាស់ប្រព័ន្ធបញ្ជូនរងរបស់ខ្លួន ក្នុងករណីដែលប្រព័ន្ធបញ្ជូននោះ មានសមត្ថភាពអាចទទួលយកបន្ទុកនោះ និងអ្នកប្រើប្រាស់យល់ព្រមបង់កម្រៃប្រើប្រាស់ និងកម្រៃផ្សេងទៀត តាមបទប្បញ្ញត្តិដែលយល់ព្រមដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។

២- ការស្នើសុំរបស់បុគ្គលណាមួយ ដែលមានបំណងភ្ជាប់ជាមួយប្រព័ន្ធបញ្ជូនរងនេះ ឬកែសម្រួលការភ្ជាប់ដែលមានស្រាប់ អ្នកកាន់អាជ្ញាប័ណ្ណត្រូវធ្វើកិច្ចសន្យាជាមួយបុគ្គលនេះ សម្រាប់ការភ្ជាប់ជាមួយប្រព័ន្ធបញ្ជូន ឬកែសម្រួលការភ្ជាប់ដែលមានស្រាប់នេះ ។ អ្នកកាន់អាជ្ញាប័ណ្ណ និងអ្នកមានបំណងប្រើប្រព័ន្ធនេះ អាចព្រមព្រៀងគ្នាលើចំណាយទាំងអស់/ចំណាយមួយផ្នែក និងរួមបញ្ចូលថ្លៃតុល្យការសម្រាប់ការកំណត់កម្រៃបញ្ជូននេះ ។

៣- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្តល់អាណត្តិកិច្ចព្រមព្រៀងឱ្យបានឆាប់រហ័សតាមតែអាចធ្វើទៅបាន ដល់អ្នកដែលចង់ប្រើប្រាស់ប្រព័ន្ធបញ្ជូនរងនេះ។ អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវកិច្ចចុះកិច្ចសន្យាណាមួយទេ ប្រសិនបើ :

ក- សមត្ថភាពបញ្ជូនមិនមានសល់នៅក្នុងប្រព័ន្ធបញ្ជូនរង ដោយហេតុថា អាចមានវិវាទណាមួយកើតឡើងចំពោះសមត្ថភាពបញ្ជូនរបស់ប្រព័ន្ធបញ្ជូនរង អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការសម្រេចចុងក្រោយដើម្បីបញ្ចប់វិវាទនេះ ។

ខ- មានការរំលោភលើច្បាប់អគ្គិសនី កូដបញ្ជូន កូដប្រព័ន្ធចែកចាយ វិធាន ឬបទប្បញ្ញត្តិពាក់ព័ន្ធនឹងសុវត្ថិភាព ឬស្តង់ដាអនុវត្តចំពោះអាជីវកម្មបញ្ជូនអគ្គិសនី ។

គ- បុគ្គលដែលកំពុងស្នើសុំមិនអនុវត្តតាមកូដប្រព័ន្ធបញ្ជូន និងកូដប្រព័ន្ធចែកចាយ ដែលបុគ្គលនោះអាចអនុវត្ត ។

ឃ-បុគ្គលដែលកំពុងស្នើសុំមិនបានបង់ថ្លៃផ្សេងៗ រួមមាន ថ្លៃកែតម្រូវការបាត់បង់ថាមពលអគ្គិសនីក្នុងប្រព័ន្ធបញ្ជូន ដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។

៤- អ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំ និងដាក់ជូនអាជ្ញាធរអគ្គិសនីកម្ពុជានូវរបាយការណ៍ប្រចាំឆ្នាំ ដែលបង្ហាញពីការព្យាករណ៍សមត្ថភាពរបស់សៀគ្វី ក្នុងរយៈពេល ៧ឆ្នាំ បន្តបន្ទាប់គ្នា អំពីលំហូរថាមពល និងបន្ទុកនៅលើផ្នែកផ្សេងៗនៃប្រព័ន្ធបញ្ជូន ស្របតាមលក្ខណៈផែនការស្តង់ដារួមជាមួយ :

## Condition 11: Condition on providing Non-discriminatory Open Access and connection to Sub-Transmission Facilities

1. The Licensee shall provide non discriminatory open access to its Sub-transmission System for use of other licensees, and the MV consumer subject to availability of transmission capacity and the user agreeing to pay all applicable charges and further subject to the regulations approved by EAC.

2. On application made for grant of a connection to the sub transmission system by any person intending to use the Sub-transmission System or modification of an existing connection, the Licensee shall offer to enter into an agreement with such person for connection to the Sub-transmission System or for modification of an existing connection. The Licensee and intended user may mutually agree for either payment of full/part connection charges and include the balance amount for determination of the transmission tariff.

3. The Licensee shall offer terms for agreements as soon as practicable to the intended users of the Sub-transmission System. The Licensee shall not be obliged to offer to enter into any agreement if :

   a) adequate transmission capacity is not available in the Sub-transmission System, provided that in case of any dispute pertaining to the existence or absence of such available capacity, the decision of EAC shall be final;

   b) it is likely to result in breach of Electricity Law, Grid Code, Distribution Code any Rules or Regulations relating to safety or Standards applicable to the Transmission Business;

   c) the person making the application does not undertake to comply with the Grid Code and Distribution Code to the extent that they are applicable to that Person; or

   d) the person making the application does not undertake to pay all applicable charges, including adjustment for losses of electricity in the Sub-transmission Systems determined by EAC.

4. The Licensee shall prepare and submit to EAC on an annual basis, a statement showing in respect of each of the seven succeeding year's forecasts of circuit capacity, power flows and loading on different elements of the Sub-transmission System

ក- ព័ត៌មានបន្ថែមដែលចាំបាច់និងសមហេតុផល ដើម្បីអាចឱ្យបុគ្គលណាមួយដែលចង់ប្រើប្រព័ន្ធនេះ អាចវិភាគ និងវាយតម្លៃលើលទ្ធភាពសម្រាប់តភ្ជាប់ និងប្រើប្រាស់ប្រព័ន្ធនេះ ។

ខ- ព័ត៌មានផ្សេងទៀតត្រូវបញ្ជាក់នៅក្នុងសេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជាជាបន្តបន្ទាប់សម្រាប់គោលបំណងនៃល័ក្ខខ័ណ្ឌនេះ ។

៥- អ្នកកាន់អាជ្ញាប័ណ្ណអាចយកសោហ៊ុយចំណាយលើការផ្តល់ ឬផ្ញើព័ត៌មានឱ្យបុគ្គលដែលមានបំណងប្រើប្រាស់ប្រព័ន្ធបញ្ជូននេះ តាមចំនួនមួយឆ្លុះបញ្ចាំងថ្លៃសមស្របសម្រាប់ចំណាយលើការផ្តល់ព័ត៌មាននេះ ។

**ល័ក្ខខ័ណ្ឌទី១២: ល័ក្ខខ័ណ្ឌគោរពតាមកូដប្រព័ន្ធបញ្ជូននិងកូដប្រព័ន្ធចែកចាយ**

១- អ្នកកាន់អាជ្ញាប័ណ្ណត្រូវគោរពតាមខ្លឹមសារដែលមានចែងនៅក្នុងកូដប្រព័ន្ធបញ្ជូន ដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។

២- ក្នុងករណីជាក់ស្តែង ក្រោយពីបានពិគ្រោះយោបល់ជាមួយអ្នកកាន់អាជ្ញាប័ណ្ណចែកចាយ អាជ្ញាធរអគ្គិសនីកម្ពុជាអាចចេញសេចក្តីណែនាំដើម្បីបន្ធូរកាតព្វកិច្ចរបស់អ្នកកាន់អាជ្ញាប័ណ្ណ ដែលត្រូវគោរពតាមកូដប្រព័ន្ធចែកចាយ ឬខ្លឹមសារដែលកំណត់ក្នុងសេចក្តីណែនាំ ។

៣- អ្នកកាន់អាជ្ញាប័ណ្ណត្រូវដំណើរការប្រព័ន្ធបញ្ជូនអគ្គិសនីស្របតាមស្តង់ដាប្រតិបត្តិដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។

**ល័ក្ខខ័ណ្ឌទី១៣: ល័ក្ខខ័ណ្ឌចំពោះថ្លៃលក់អគ្គិសនីសម្រាប់សេវាកម្មបញ្ជូន និងសេវាកម្មលក់ដុំ**

១- អ្នកកាន់អាជ្ញាប័ណ្ណត្រូវអនុវត្តបញ្ជីថ្លៃលក់អគ្គិសនី សម្រាប់សេវាកម្មបញ្ជូន ដូចមានចែងក្នុងកិច្ចព្រមព្រៀងបញ្ជូនដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។ ក្នុងករណីដែលសេវាកម្មបញ្ជូននេះពុំមានកិច្ចព្រមព្រៀង ដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា ឬកិច្ចព្រមព្រៀងដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា ពុំមានកំណត់ពីបញ្ជីថ្លៃលក់អគ្គិសនី អ្នកកាន់អាជ្ញាប័ណ្ណត្រូវស្នើសុំអាជ្ញាធរអគ្គិសនីកម្ពុជាដើម្បីកំណត់បញ្ជីថ្លៃលក់អគ្គិសនី ហើយត្រូវអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជានេះជាបន្តបន្ទាប់ ។

២- អ្នកកាន់អាជ្ញាប័ណ្ណត្រូវអនុវត្តបញ្ជីថ្លៃលក់អគ្គិសនី សម្រាប់លក់ឱ្យអតិថិជនតង់ស្យុងមធ្យម ឬអ្នកកាន់អាជ្ញាប័ណ្ណដទៃដូចមានចែងក្នុងកិច្ចព្រមព្រៀងផ្គត់ផ្គង់អគ្គិសនី ដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។ ក្នុងករណីការលក់អគ្គិសនីនេះ ពុំមានកិច្ចព្រមព្រៀងដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា ឬកិច្ចព្រមព្រៀងដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា ពុំមានកំណត់ពីបញ្ជីថ្លៃលក់អគ្គិសនី អ្នកកាន់អាជ្ញាប័ណ្ណ

under standard planning criteria, together with:

a) such further information as shall be reasonably necessary to enable any person seeking use of System to identify and evaluate the opportunities available when connecting to and making use of such system; and

b) such other information as shall be specified in directions issued by EAC from time to time for the purpose of this condition.

5. The Licensee may make a charge for any statement given or sent to persons seeking use of the Sub-transmission System, of an amount reflecting the Licensee's reasonable costs of providing such a statement.

**Condition 12: Conditions on compliance with Grid Code, Distribution Codes and Operating Standard**

1. The Licensee shall comply with the provisions of the Grid Code and Distribution Code approved by EAC.

2. In specific case, EAC may (following consultation with concerned licensee) issue directions relieving the Licensee of its obligation to comply with certain provisions of Grid Code or Distribution Code as specified in the directions.

3. The Licensee shall operate the Sub-transmission System in accordance with the Operating Standards approved by EAC.

**Condition 13: Condition on Tariff for transmission /wheeling service and Bulk Sale**

1. The Licensee shall implement the tariff for the transmission/wheeling service as provided in the Transmission /Wheeling Agreement approved by EAC. In case, for a transmission/Wheeling service, there is no Transmission/ Wheeling Agreement approved by EAC or the Transmission /wheeling Agreement approved by EAC does not provide the tariff, the Licensee shall request EAC to determine the tariff and shall implement the tariff approved by EAC from time to time.

2. The Licensee shall implement the tariff for sale of electricity to MV consumers or other licensees as provided in the Supply Agreement approved by EAC. In case, for a sale of electricity, there is no Supply Agreement approved by EAC or the Supply Agreement approved by EAC does not provide the tariff, the Licensee shall request EAC to determine the tariff and shall

ត្រូវស្នើសុំអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីកំណត់បញ្ជីថ្លៃលក់អគ្គិសនី ហើយត្រូវអនុវត្តបញ្ជីថ្លៃលក់អគ្គិសនី ដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជានេះជាបន្តបន្ទាប់ ។

**លក្ខខណ្ឌទី១៤ : ការដោះស្រាយវិវាទពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងបញ្ជូន ឬកិច្ចព្រមព្រៀងផ្គត់ផ្គង់អគ្គិសនី**

១- វិវាទ ឬជម្លោះណាមួយរវាងអ្នកកាន់អាជ្ញាប័ណ្ណ និងភាគីចុះកិច្ចព្រមព្រៀងបញ្ជូន ឬកិច្ចព្រមព្រៀងផ្គត់ផ្គង់អគ្គិសនី ពាក់ព័ន្ធនឹងព្រមព្រៀងបញ្ជូន ឬកិច្ចព្រមព្រៀងផ្គត់ផ្គង់អគ្គិសនីនេះ ត្រូវដោះស្រាយស្របតាមខ្លឹមសារដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះ ។

## ៤. លក្ខខណ្ឌសេវាកម្មសម្រាប់អាជ្ញាប័ណ្ណចែកចាយ

**លក្ខខណ្ឌទី១៥: លក្ខខណ្ឌចំពោះតំបន់ធ្វើសេវាកម្ម**

១- អាជ្ញាប័ណ្ណនេះផ្តល់សិទ្ធិឱ្យអ្នកកាន់អាជ្ញាប័ណ្ណ មានសិទ្ធិធ្វើសេវាកម្មចែកចាយអគ្គិសនីនៅតំបន់ស្រុកត្បូងឃ្មុំ និងតំបន់ស្រុកអូររាំងឪ ខេត្តកំពង់ចាម ។

២- អ្នកប្រើប្រាស់ធុនធំ និងអ្នកប្រើប្រាស់ដុំក្នុងតំបន់ចែកចាយខាងលើ ដូចមានកំណត់ទីតាំងច្បាស់លាស់ក្នុងឧបសម្ព័ន្ធ២ អាចមានសិទ្ធិជ្រើសរើសប្រភពផ្គត់ផ្គង់ពីប្រព័ន្ធបញ្ជូន/ ប្រព័ន្ធបញ្ជូនរង ឬពីប្រព័ន្ធចែកចាយមេផ្សេងទៀតបាន បើសិនជាមានការយល់ព្រមពីអាជ្ញាធរអគ្គិសនីកម្ពុជា ។

**លក្ខខណ្ឌទី១៦: លក្ខខណ្ឌចំពោះមធ្យោបាយធ្វើសេវាកម្ម**

១- អ្នកកាន់អាជ្ញាប័ណ្ណ មានកាតព្វកិច្ចអភិវឌ្ឍន៍មធ្យោបាយធ្វើសេវាកម្មរបស់ខ្លួន ដើម្បីអាចផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់របស់ខ្លួនបាន និងប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព ។ អ្នកកាន់អាជ្ញាប័ណ្ណត្រូវធ្វើផែនការ និងអភិវឌ្ឍន៍ប្រព័ន្ធចែកចាយរបស់ខ្លួន ទៅតាមស្តង់ដាបច្ចេកទេសអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា ដែលរៀបចំ និងប្រកាសឱ្យប្រើដោយក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ។

២- អ្នកកាន់អាជ្ញាប័ណ្ណត្រូវពង្រីក និងកែលំអប្រព័ន្ធចែកចាយរបស់ខ្លួនតាមកម្មវិធីដែលបានការយល់ព្រមពីអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីធានាការផ្គត់ផ្គង់អគ្គិសនីដល់គ្រប់អ្នកប្រើប្រាស់ក្នុងតំបន់ ។

**លក្ខខណ្ឌទី១៧ : លក្ខខណ្ឌចំពោះកិច្ចដំណើរការប្រព័ន្ធចែកចាយ**

១- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវដំណើរការការផ្គត់ផ្គង់ និងការចែកចាយរបស់ខ្លួនតាមស្តង់ដាប្រតិបត្តិមួយ ដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា អនុលោមតាមមាត្រា៣ និង៧ (ង) របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។

២- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវរៀបចំឱ្យមានប្រភពអគ្គិសនីគ្រប់គ្រាន់មួយសំរាប់ផ្គត់ផ្គង់ឱ្យអតិថិជនរបស់ខ្លួន ។ អ្នកកាន់អាជ្ញាប័ណ្ណត្រូវធានានូវល័ក្ខខ័ណ្ឌដូចខាងក្រោម :

implement the tariff approved by EAC from time to time.

**Condition 14: Settlement of Disputes relating to Transmission/Wheeling or Supply Agreement**

1. Any dispute or difference between Licensee and a party to the Transmission/Wheeling or Supply Agreement relating to the Agreement shall be settled according to the provisions in that agreement.

## 4-SERVICE CONDITIONS FOR DISTRIBUTION LICENSE

**Condition 15: Condition on electric power service area**

1. This license grants the right to the Licensee to distribute electric power in Tbong Khmum District Area and Oreang Ov District Area, Kampong Cham province.

2. Big consumers and bulk consumers in the distribution area indicated in Schedule 2 have the right to select other supply sources from the transmission line/sub-transmission line or distribution network of other licensees, if they obtain prior approval from EAC.

**Condition 16: Conditions on electric power service utilities**

1. The Licensee shall have the obligation to develop its distribution system in order to supply electricity to its consumers with efficiency and security. The Licensee shall plan and develop its distribution system in conformity with the Electric Power Technical Standards of the Kingdom of Cambodia issued by Ministry of Industry, Mines and Energy.

2. The Licensee shall extend and improve its distribution network in accordance with its plan approved by EAC to ensure electricity supply to all consumers in the area of distribution.

**Condition17: Conditions on distribution system operation**

1. The Licensee shall conduct its Supply and Distribution Operation to meet the standards of performance determined by EAC pursuant to Article 3 and 7(e) of the Electricity Law of the Kingdom of Cambodia.

2. The Licensee shall make available sufficient electricity for supply to its consumers. Licensee shall ensure the following

(ក)- មិនត្រូវមានការកាត់ផ្តាច់លើសពីរយៈពេលស្តង់ដា ដែលបានអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា និង

(ខ)- តង់ស្យុង និងហ្វ្រេកង់អគ្គិសនី មិនត្រូវហួសពីកំរិតព្រំដែនដំណើរការជាធម្មតាដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា ឡើយ ។

៣- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវគោរពតាមកូដប្រព័ន្ធចែកចាយមួយ ដែលអាជ្ញាធរអគ្គិសនីកម្ពុជានឹងកំណត់នៅពេលក្រោយ ។

**លក្ខខណ្ឌទី១៨ : លក្ខខណ្ឌចំពោះការផ្គត់ផ្គង់អគ្គិសនីឱ្យអតិថិជន**

១- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវគោរពតាមបទប្បញ្ញត្តិរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ស្តីពីល័ក្ខខ័ណ្ឌទូទៅក្នុងការផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- ក្នុងការចែកចាយអគ្គិសនី អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវរើសអើងរវាងបុគ្គល ឬក្រុមបុគ្គលណាមួយជាមួយបុគ្គល ឬក្រុមបុគ្គលណាមួយទៀតឡើយ ។

៣- អ្នកកាន់អាជ្ញាប័ណ្ណ (និងធានាថាភ្នាក់ងាររបស់ខ្លួន) ត្រូវធ្វើសកម្មភាពយ៉ាងណាសមស្របដើម្បីការពារ និងទប់ទល់នឹង :

(ក)-ការលួចអគ្គិសនីនៅចំណុចផ្គត់ផ្គង់

(ខ)-ការធ្វើឱ្យខូចខាតបរិក្ខារអគ្គិសនី, ខ្សែបណ្តាញឬនាឡិកាស្ទង់ណាមួយដែលតាមរយៈវា អតិថិជនបានទទួលការផ្គត់ផ្គង់

(គ)-ការប៉ះពាល់ដល់នាឡិកាស្ទង់ណាមួយ ដែលតាមរយៈវា អតិថិជនបានទទួលការផ្គត់ផ្គង់

៤- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវបញ្ចូលក្នុងបញ្ញត្តិនៃកិច្ចសន្យាផ្គត់ផ្គង់ជាមួយអតិថិជនថា អតិថិជនត្រូវផ្តល់ព័ត៌មានឱ្យបានឆាប់រហ័សតាមដែលអាចអនុវត្តទៅបានឱ្យអ្នកកាន់អាជ្ញាប័ណ្ណនូវឧប្បត្តិហេតុណាមួយ ដែលគេជឿជាក់ថា :

(ក)-មានការខូចខាតបរិក្ខារអគ្គិសនី ខ្សែបណ្តាញ ឬនាឡិកាស្ទង់អគ្គិសនី ឬ

(ខ)-មានការប៉ះពាល់នាឡិកាស្ទង់ ដោយធ្វើឱ្យលំអៀងដល់ការកត់ត្រា ឬទប់ស្កាត់មិនឱ្យកត់ត្រាបរិមាណអគ្គិសនីដែលបានផ្គត់ផ្គង់

៥- អ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំ និងដាក់ជូនអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីស្នើសុំការយល់ព្រមលើនីតិវិធីរបស់ខ្លួន សំរាប់ដោះស្រាយពាក្យបណ្តឹងរបស់អតិថិជនចំពោះខ្លួន ។

៦- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវបង្កើតនិងដំណើរការនូវសេវាផ្តល់ព័ត៌មានមួយ សំរាប់ផ្តល់ព័ត៌មានឱ្យអតិថិជនណាមួយដែលចង់ដឹងពីព័ត៌មាន ការណែនាំ ឬការផ្តល់យោបល់ពីបញ្ហាណាមួយឬឧបត្តិហេតុណាមួយ

conditions:

a) Supply will not be discontinued for more than the permissible time approved by EAC; and

b) The voltage or frequency of electricity will not go beyond the operational limits approved by EAC.

3. The Licensee shall comply with the Distribution Code approved by EAC.

**Condition 18: Condition on electric power supply to customer**

1. The Licensee shall comply with the EAC's Regulation on general conditions of supply of electricity in the Kingdom of Cambodia.

2. In the provision of electricity, the Licensee shall not discriminate between persons or classes of person.

3. The Licensee shall (and shall ensure that its agents) take all reasonable steps to detect and prevent:

a) the theft of electricity at the point of supply

b) damage to any electrical plant, electric line or electricity meter through which the consumer is supplied; and

c) interference with any electricity meter through which such premises are supplied.

4. The Licensee shall include in the provisions of supply contract with the customer that the customer shall, as soon as is reasonably practicable and possible, inform the Licensee of any incident where it has reason to believe:

a) there has been damage to electrical plant, electric line or meter; or

b) there has been interference with the meter to alter its register or prevent it from duly registering the quantity of electricity supplied.

5. The Licensee shall prepare and submit to EAC its procedure for handling complaint from customers for approval.

6. The Licensee shall establish and operate an information service for use by any customer for the purposes of receiving

| | |
|---|---|
| ក្នុងសេវាកម្មចែកចាយអគ្គិសនីរបស់ខ្លួន ។ | information, guidance or advice about any matter or incident in its distribution service. |